CITY OF LONG BEACH **PRESS RELEASE**

**សេចក្ដីប្រកាសព័ត៌មាន**

ថ្ងៃទី ៣០ ខែមិថុនាឆ្នាំ ២០២០

ទំនាក់ទំនង៖ Jennifer Carey, មន្ត្រីទំនាក់ទំនងសហគមន៍, 562.570.3233,
Jennifer.Carey@longbeach.gov

សម្រាប់សេចក្ដីប្រកាសជាបន្ទាន់

# មជ្ឈមណ្ឌលសហគមន៍នៅ Houghton Park ដែលត្រូវបានពង្រីកបានត្រូវបើកបង្ហាញតាមអ៊ីនធឺណិត

ទីក្រុងឡុងប៊ិច, រដ្ឋកាលីហ្វ័រញ៉ា - ថ្ងៃនេះតាមរយៈការផ្សាយបន្តផ្ទាល់ទីក្រុងឡុងប៊ិចបានបើកបង្ហាញមជ្ឈមណ្ឌលសហគមន៍ Houghton Park (6301 Myrtle Avenue)។

លោកអភិបាលក្រុង Robert Garcia បានមានប្រសាសន៍ថា "មជ្ឈមណ្ឌលសហគមន៍នៅ Houghton Park របស់យើងគឺអាចធ្វើទៅបានដោយមួយផ្នែកដោយបានថវិកាពី Measure A។ ទីធ្លាសហគមន៍ដែលមានគុណភាពដូចនេះមានសារៈសំខាន់សម្រាប់កុមារនិងក្រុមគ្រួសារហើយខ្ញុំមានមោទនភាពចំពោះទីក្រុងរបស់យើងដែលបានផ្ដល់អគារដែលមានវិញ្ញាបនប័ត្រភាពជាអ្នកដឹកនាំក្នុងការរចនាទាំងផ្នែកថាមពលនិងបរិស្ថានទៅដល់ទីក្រុងឡុងប៊ិចប៉ែកខាងជើង។"

មជ្ឈមណ្ឌលសហគមន៍ដែលបានពង្រីកនឹងតភ្ជាប់ទៅមជ្ឈមណ្ឌលសហគមន៍ដែលមានស្រាប់តាមរយៈផ្លូវខ្យល់ហើយនឹងព័ទ្ធជុំវិញផ្នែកប្រវត្តិសាស្ត្រនៃអគារដែលបានសាងសង់តាំងពីឆ្នាំ ១៩៣០។ មជ្ឈមណ្ឌលសហគមន៍នេះមានបន្ទប់ពហុមុខងារធំៗពីរដែលអាចប្រើបានច្រើនយ៉ាង។ វាក៏នឹងមានមជ្ឈមណ្ឌលយុវវ័យបន្ទប់កុំព្យូទ័រនិងបន្ទប់លើកទំងន់ផងដែរ។

សមាជិកក្រុមប្រឹក្សាក្រុងលោក Rex Richardson បានមានប្រសាសន៍ថា "ការបើកមជ្ឈមណ្ឌលសហគមន៍ Houghton Park ថ្មីគឺជាសក្ខីភាពនៃការធ្វើផែនការជាសហគមន៍និងការតស៊ូមតិជាច្រើនឆ្នាំនៅភាគខាងជើងទីក្រុងឡុងប៊ិចនេះ។ សហគមន៍យើងឥឡូវជាទីលំនៅរបស់មជ្ឈមណ្ឌលសហគមន៍ថ្មីនិងធំជាងគេបំផុតរបស់ទីក្រុងដែលស្ថិតនៅទីតាំងដែលជាប្រវត្តិសាស្ត្រសំខាន់។ ខ្ញុំទន្ទឹងរង់ចាំការអបអរជាមួយអ្នកជិតខាងរបស់យើងនៅពេលដែលយើងអាចបើកមណ្ឌលសហគមន៍នេះឲ្យបានពេញលេញជាសាធារណៈ។"

ការរចនាមជ្ឈមណ្ឌលសហគមន៍នេះគឺបានសាងសង់ដោយគំនិតនៃនិរន្តរភាពនិងប្រសិទ្ធភាពផ្នែកថាមពលក្នុងកំនិតហើយអគារនេះក៏ទទួលបានចំណាត់ថ្នាក់ពណ៌ប្រាក់សម្រាប់ភាពជាអ្នកដឹកនាំក្នុងការរចនាទាំងផ្នែកថាមពលនិងបរិស្ថាន (LEED)។ រុក្ខជាតិធន់នឹងគ្រោះរាំងស្ងួតដែលបានដាំនៅជុំវិញអាគារនិងទីធ្លាខាងក្រៅនឹងកាត់បន្ថយការប្រើប្រាស់ទឹកហើយបន្ទះដែលធ្វើពីសារធាតុប៉ូលីកាបូណានឹងនាំពន្លឺថ្ងៃធម្មជាតិចូលទៅក្នុងបន្ទប់ពហុមុខងារនិងកាត់បន្ថយចំណាយលើថ្លៃភ្លើង។

ការងាយស្រួលក្នុងការចតរថយន្តត្រូវបានធ្វើឱ្យប្រសើរឡើងតាមរយៈការបន្ថែមកន្លែងចំណតសម្រាប់រថយន្តអគ្គិសនី រៀបចំឡើងវិញនូវកន្លែងទម្លាក់និងកន្លែងមកយកសម្រាប់ឡានសាលា និងបន្ថែមកន្លែងចតសម្រាប់កង់បន្ថែមទៀតដើម្បីសម្របសម្រួលដល់របៀបធ្វើដំណើរផ្សេងៗ។

ក្រសួងសាធារណការបានចាប់ផ្តើមសាងសង់អគារថ្មីទំហំ ៦.៤៥០ ហ្វីតការ៉េកាលពីខែមីនាឆ្នាំ ២០១៨។ គម្រោងនេះអាចធ្វើទៅបានដោយថវិកាចំនួន ៥.៧៤១.៨៩៦ ដុល្លារពី Measure A និង ៤.៤៨២.៦១២ ដុល្លារពីប្រភពផ្តល់មូលនិធិផ្សេងទៀតរួមទាំងថវិកាផ្តល់តែម្តង។

**អំពីក្រសួងឧទ្យានកំសាន្តនិងសមុទ្រនៃទីក្រុងឡុងប៊ិច**

មន្ទីឧទ្យានកំសាន្តនិងសមុទ្រនៃទីក្រុងឡុងប៊ិច (PRM) ត្រូវបានទទួលស្គាល់ចំពោះឧត្តមភាពក្នុងការអនុវត្តការគ្រប់គ្រងនិងកម្មវិធីដោយទទួលបានពានរង្វាន់មេដាយមាសឧទ្យាននិងសួនកំសាន្តជាតិបួនដង។ PRM ផ្តល់នូវកម្មវិធីនិងសេវាកម្មកម្សាន្តដល់ប្រជាជននិងភ្ញៀវទេសចរដែលធ្វើអោយគុណភាពជីវិតនៃការរស់នៅឡុងប៊ិចកាន់តែប្រសើរឡើង។ PRM ថែរក្សាឧទ្យានចំនួន 171 កន្លែងដែលមានមជ្ឈមណ្ឌលសហគមន៍ចំនួន 26 ទីធ្លាបើកចំហ 320 ហិចតានិងឆ្នេរ 6.1 ម៉ាយល៍ក៏ដូចជាអនុវត្ត

ផែនការបើកលំហរបស់ទីក្រុងផ្តល់នូវឱកាសកំសាន្តដើម្បីបំពេញតំរូវការសហគមន៍ផ្សេងៗរក្សានូវសមុទ្រសាធារណៈនិងផ្តល់នូវសុវត្ថិភាពសាធារណៈនិងការព្យាបាលដោយមនុស្សធម៌ដល់សត្វ។

សម្រាប់ព័ត៌មានបន្ថែមអំពីមន្ទីឧទ្យានកំសាន្តនិងសមុទ្រនៃទីក្រុងឡុងប៊ិចសូមចូលទៅកាន់គេហទំព័រ http://www.longbeach.gov/park។ សូមតាមដានយើងខ្ញុំនៅលើបណ្តាញសង្គមដើម្បីទទួលបាននូវព័ត៌មានថ្មីៗតាមរយៈបណ្តាញសង្គមហ្វេសប៊ុក ធ្វីតធឺរ Instagram និងយូធ្យូប។

**អំពីក្រសួងសាធារណការ**

ក្រសួងសាធារណការនៃទីក្រុងឡុងប៊ិចខិតខំថែរក្សានិងលើកកំពស់ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តនិងដឹកជញ្ជូនក្នុងទីក្រុងក៏ដូចជាថែរក្សាទេសភាពទីក្រុងដោយមានសេវាកម្មប្រមូលសំរាមនិងរបស់ដែលអាចយកទៅកែឆ្នៃបានដល់រឹងមាំដែលបម្រើអតិថិជនជាង ១២០.០០០ អ្នកដែលរួមមានពលរដ្ឋនិងពាណិជ្ជកម្មផ្សេងៗ។ ក្រសួងនេះផ្តល់ជូននូវសេវាកម្មសហគមន៍ជាច្រើនប្រភេទរួមមានការជួសជុលការស្តារឡើងវិញ និងការថែរក្សាផ្លូវទូទៅក្នុងក្រុងដើមឈើចិញ្ចើមផ្លូវនិងរចនាសម្ព័ន្ធរបស់ទីក្រុង។ ក្រសួងសាធារណការក៏មានមុខងារផ្តល់សេវាកម្មគាំទ្រជាបន្ទាន់នៅទូទាំងទីក្រុងផងដែរ។

សម្រាប់ព័ត៌មានបន្ថែមអំពីក្រសួងសាធារណការសូមមេត្តាចូលទៅកាន់គេហទំព័រ http://www.longbeach.gov/pw/ សូមចុច "Like" នៅលើបណ្តាញសង្គម ហ្វេសប៊ុក របស់ក្រសួងយើងខ្ញុំនិងតាមដានយើងខ្ញុំនៅលើ ធ្វីតធ័រ និង Instagram។

**អំពីទីក្រុងឡុងប៊ិច**

ជាទីលំនៅដ្ឋាននៃប្រជាជនប្រមាណ ៤៨០,០០០ នាក់ទីក្រុងឡុងប៊ិចបានទទួលពានរង្វាន់និងជាទីក្រុងច្នៃប្រឌិតដែលផ្តល់ជូននូវភាពសំបូរបែបនៃពិភពលោកខណៈពេលដែលរក្សាលក្ខណៈបុគ្គលនិងដែលបង្កើតឡើងពីសង្កាត់ផ្សេងៗពីគ្នាដែលបានផ្តុំនៅតាមបណ្តោយឆ្នេរសមុទ្រប៉ាស៊ីហ្វិក។ ក្នុងនាមជាទីក្រុងដែលមានសេវាកម្មពេញលេញទីក្រុងឡុងប៊ិចជាលំនៅដ្ឋានរបស់នាវា Queen Mary, អាងចិញ្ចឹមត្រីនៃមហាសមុទ្រប៉ាស៊ីហ្វិក (Aquarium of the Pacific), សារមន្ទីរនិងរោងកុនជាច្រើន, សាលារៀនដែលត្រូវបានវាយតម្លៃខ្ពស់, អាកាសយានដ្ឋានឡុងប៊ិច, កំពង់ផែឡុងប៊ិច ក៏ដូចជាមន្ទីរផ្សេងៗដែលបានទទួលពានរង្វាន់ជាច្រើនដូចជាមន្ទីរសុខាភិបាល មន្ទីរឧទ្យានការកំសាន្តនិងសមុទ្រ មន្ទីរសេវាកម្មអភិវឌ្ឍន៍ និងមន្ទីរផ្សេងៗទៀត។ ទីក្រុងនេះក៏មានសាកលវិទ្យាល័យនិងមហាវិទ្យាល័យដែលត្រូវបាន

ការគោរពខ្ពស់ ក៏ដូចជាកន្លែងចិញ្ចឹមសត្វជាប្រវត្តិសាស្រ្តចំនួន២ មន្ទីរពេទ្យ៥ ទីតាំង៥សម្រាប់លេង ហ្គោល សួន១៧០ ឆ្នេរសមុទ្រជាច្រើនម៉ាយល៍ម៉ា ផ្លូវសម្រាប់ជិះកង់ និងកម្មវិធីជិះកង់ដែលមានការចែករំលែក។

សម្រាប់ព័ត៌មានបន្ថែមអំពីទីក្រុងឡុងប៊ិចសូមចូលទៅកាន់គេហទំព័រ http://longbeach.gov/។ សូមតាមដានទីក្រុងឡុងប៊ិចនៅលើបណ្តាញសង្គមសម្រាប់ព័ត៌មានថ្មីៗនៅលើ ហ្វេសប៊ុក ធ្វីតធ័រ Instagram និង យូធ្យូប។

# # #